ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង៖ ២៨/១២-អល ស៊ូបភើ អ៊ិនធើប្រាយ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២
យោបល់ជំទាស់ទៅនឹងសេចក្តីបង្គាប់ ៖ ដោយអាជ្ញាកណ្តាល អ៊ឹង សុទ្ធី

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ អាំង អេងថុង

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន អល ស៊ូបភើ អ៊ិនធើប្រាយ (ខេមបូឌា) ខូអិលធីឌី
អាសយដ្ឋាន ៖ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៧៩៤ ០២៩ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

- លោកស្រី អ៊ូច ចាន់ដាវី ប្រធានផ្នែករដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ
- សហជីពស្មារតីកម្មករខ្មែរនៃក្រុមហ៊ុន អល ស៊ូបភើ

អាសយដ្ឋាន ៖ ផ្ទះលេខ៣៥៨ ផ្លូវលំ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៧ ៤៣ ០៣ ១២ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖

១- លោក ហ៊ីង ប៊ុនធឿន អនុប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ

២- លោក នុំ សេងគាង មន្ត្រីសម្របសម្រួលសហព័ន្ធសហជីពស្ការតីកម្មករខ្មែរ

៣- លោក ឃួន លី ប្រធានសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន អលស្ទីបភើ

៤- លោក សៅ រតនា អនុប្រធានសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន

៥- លោក ធា ផុល លេខាសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនទទួលយកលោក ឃួន លី ដែលជាថ្នាក់ដឹកនាំសហជីពស្មារតីកម្មករខ្មែរចូលធ្វើការវិញជាធម្មតា និងរក្សាអត្ថប្រយោជន៍ផ្សេងៗនៅដដែល ។ ដោយឡែក ភាគីក្រុមហ៊ុនបញ្ជាក់ថាមិនអាចទទួលយកលោក ឃួន លី ចូលធ្វើការវិញឡើយ ដោយរង់ចាំការសម្រេចរបស់អធិការការងារ ។

២- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារ ក្នុងមួយខែ ។ ដោយឡែក ក្រុមហ៊ុនសុំអនុវត្តតាមច្បាប់ ។

៣- កម្មករនិយោជិតទាមទារ នៅពេលសុំច្បាប់ធម្មតា សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ធ្វើការទៀងទាត់សមាមាត្រទៅតាមចំនួនថ្ងៃ ដែលបានឈប់ ។ ដោយឡែក ភាគីក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់ ។

៤- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃស្នាក់នៅ និងប្រាក់សោហ៊ុយធ្វើដំណើរចំនួន ២០ ដុល្លារ ក្នុងមួយខែ ។ ដោយឡែក ភាគីក្រុមហ៊ុនបញ្ជាក់ថា ពុំមានលទ្ធភាពផ្តល់ជូនទេ ។

៥- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ប្រចាំខែបន្ថែមជូនប្រធានក្រុម និងកម្មករនិយោជិតគ្រប់ក្រុម គ្រប់ផ្នែក ។ ដោយឡែក ភាគីក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់ ។

៦- ចំពោះកម្មការិនី ដែលមានផ្ទៃពោះចាប់ពីមួយខែកន្លះទៅ សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យគាត់ទៅពិនិត្យសុខភាពមួយថ្ងៃក្នុងមួយខែ ដោយរក្សាអត្ថប្រយោជន៍ផ្សេងៗនៅដដែល ។ ដោយឡែក ភាគីក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់ ។

៧- សុំឱ្យក្រុមហ៊ុនចាក់បទចម្រៀងជូនកម្មករនិយោជិតស្តាប់នៅរៀងរាល់ម៉ោងធ្វើការងារ ។ ដោយឡែក ភាគីក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់ ។

៨- នៅថ្ងៃទី០៨ មីនា (បុណ្យសិទ្ធិនារី) សុំឱ្យក្រុមហ៊ុនរៀបចំកម្មវិធីជប់លៀង និងធ្វើការចាប់រង្វាន់ផ្សេងៗជូនកម្មករ ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចរៀបចំបានទេ ។

៩- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យកម្មករនិយោជិតទៅពិនិត្យសុខភាពជាពិសេសក្នុងមួយឆ្នាំ២ដង ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ទាក់ទងការពិនិត្យសុខភាពជាពិសេស ក្រុមហ៊ុននឹងពិនិត្យទៅលើភាពជាក់ស្តែង ។

THE ARBITRATION COUNCIL

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៦៧ កប/អក/វក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួន។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សានៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ ដោយទទួលបានលទ្ធផលមិនសះជាចំនួន ០៩ ចំណុច លើការទាមទារចំនួន ១០ ចំណុច។ ចំណុចមិនសះជាចំនួន ០៩ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១៦៧ កប/អក/វក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២។

បន្ទាប់ពីបានទទួលសំណុំរឿងមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកចូលរួមសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៩ ចំណុចនេះ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង ២ រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៩ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជាចំនួន ១ ចំណុច គឺចំណុចវិវាទទី ៦ និង មិនសះជាចំនួន ៨ ចំណុច គឺចំណុចវិវាទទី១ ចំណុចវិវាទទី២ ចំណុចវិវាទទី៣ ចំណុចវិវាទទី៤ ចំណុចវិវាទទី៥ ចំណុចវិវាទទី៧ ចំណុចវិវាទទី៨ និង ចំណុចវិវាទទី៩ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយដោយផ្អែកលើភស្តុតាង និងការបកស្រាយបំភ្លឺរបស់ភាគីកម្មករនិយោជិតនៅក្នុងសវនាការ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន អល ស៊ូបភើ អ៊ិនធើប្រាយ ផ្ទេរសិទ្ធិជូនលោកស្រី អ៊ូច ចាន់ដាវី ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១២។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ ២៩៨៦ ពណ.ចបព ចុះខែមិថុនា ឆ្នាំ២០១១។

៣- លក្ខន្តិកៈក្រុមហ៊ុន អល ស៊ូបភើ អ៊ិនធើប្រាយ។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន បានឃើញ និងបញ្ជាក់ថា ត្រឹមត្រូវ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ លេខ ១៦៨ កប/អក/អធក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧។

៥- លិខិតជូនដំណឹងរបស់ក្រុមហ៊ុន អល ស៊ូបភើ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ ជូនលោក ឃួន លី ស្ដីពីការសម្រេចព្យួរការងាររបស់លោក ឃួន លី។

៦- លិខិតរបស់ក្រុមហ៊ុន អល ស៊ូបភើ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្ដីពីសំណើសុំព្យួរការងារ លោក ឃួន លី។

៧- លិខិតរបស់ក្រុមហ៊ុន អល ស៊ូបភើ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្ដីពីសំណើសុំបញ្ឈប់ការងារ លោក ឃួន លី។

៨- លិខិតលើកពេលផ្សះផ្សារបស់ភាគីក្រុមហ៊ុន និងសហជីពនៅក្រុមហ៊ុន អល ស៊ូបភើ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១២។

៩- កំណត់ហេតុសាកសួរព័ត៌មានពីតំណាងនិយោជកនៃក្រុមហ៊ុន អល ស៊ូបភើ របស់នាយកដ្ឋានវិវាទការងារ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២។

១០- លិខិតលេខ ១៩២ កប/អក/វក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក នាយកក្រុមហ៊ុន អល ស៊ូបភើ ស្ដីពីការស្នើសុំបញ្ឈប់លោក ឃួន លី។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតលេខ ០១៣ សសសកខ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ របស់សហព័ន្ធសហជីពសេរីកម្មករខ្មែរ គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្ដីពីការស្នើសុំជួយដោះស្រាយសម្របសម្រួលនូវវិវាទ

ការងារ ចំនួន ១០ ចំណុច របស់ក្រុមហ៊ុន អល ស៊ូបភើ ។

២- លិខិតលេខ ០១២ សសសកខ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ របស់សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ គោរពជូន នាយកក្រុមហ៊ុន អល ស៊ូបភើ ស្តីពីការស្នើសុំជួយដោះស្រាយសម្របសម្រួលនូវវិវាទការងារចំនួន ១០ ចំណុច របស់ក្រុមហ៊ុន អល ស៊ូបភើ ។

៣- លិខិតពឹងពាក់ និងជួយអមរបស់កម្មករ កម្មការិនីនៃរោងចក្រ អល ស៊ូបភើ (ចំនួន២៧១នាក់) ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ គោរពជូន ប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ដើម្បីឱ្យសហព័ន្ធជួយសម្របសម្រួលជាមួយក្រុមហ៊ុន ក្រុមប្រឹក្សាអាជ្ញាកណ្តាល តុលាការ អាជ្ញាធរ និងស្ថាប័នគ្រប់ជាន់ថ្នាក់ ដែលពាក់ព័ន្ធនូវករណីវិវាទការងារចំនួន ១០ ចំណុច ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អល ស៊ូបភើ លេខ ១៦៧ កប/អក/វក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន អល ស៊ូបភើ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៦៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៦៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា**

- ក្រុមហ៊ុន អល ស៊ូបភើ អ៊ិនធើប្រាយ (ខេមបូឌា)គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតចំនួនប្រមាណ ១៥០០ នាក់ ។
- សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ។ សហជីពនេះ ពុំទាន់មានបញ្ជិកាសហជីពនៅឡើយទេ ។ មានកម្មករនិយោជិតចំនួន ២៥៨ នាក់ ដែលបានពឹងពាក់សហជីពស្មារតីកម្មករខ្មែរក្នុងការនាំបណ្តឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

THE ARBITRATION COUNCIL

ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារសុំឱ្យនិយោជកទទួលលោក ឃួន លី ដែលជាថ្នាក់ដឹកនាំសហជីពស្មារតីកម្មករខ្មែរចូលធ្វើការវិញជាធម្មតា និងរក្សាអត្ថប្រយោជន៍ផ្សេងៗនៅដដែល

- កម្មករ ឃួន លី ចូលធ្វើការនៅក្នុងក្រុមហ៊ុន អល ស៊ូបភើ អ៊ិនធើប្រាយ (ខេមបូឌា) នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ដែលមានប្រភេទកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ និងមានមុខនាទីជាមេកន្ត្រៃ ផ្នែកតុកាត់។ ក្រៅពីតួនាទីជាមេកន្ត្រៃនៅផ្នែកតុកាត់ កម្មករ ឃួន លី មានតួនាទីជាតំណាងប្រតិភូបុគ្គលិក។
- នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ និយោជកបានព្យួរកិច្ចសន្យាការងារកម្មករ ឃួន លី ដោយរង់ចាំសេចក្តីសម្រេចបញ្ឈប់គាត់ពីអធិការការងារ។
- នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ និយោជកបានផ្ញើរលិខិតសុំបញ្ឈប់កម្មករ ឃួន លី ទៅប្រធាននាយកដ្ឋានវិវាទការងារ។
- នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារបានចេញសេចក្តីសម្រេចមួយ ដោយយល់ព្រមទៅនឹងការស្នើសុំបញ្ឈប់កម្មករ ឃួន លី ពីការងារ។
- ភាគីនិយោជកបានបញ្ជាក់ពីមូលហេតុនៃការបញ្ឈប់នេះថា៖
  - ថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១១ កម្មករ ឃួន លី បានឈប់ឥតច្បាប់ចំនួន ៤ថ្ងៃ។
  - ថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១១ កម្មករ ឃួន លី បានឈប់ឥតច្បាប់ចំនួន ៣ ថ្ងៃទៀត។
  - នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ កម្មករ ឃួន លី បានឈប់ឥតច្បាប់ចំនួនមួយថ្ងៃទៀត។
  - នៅថ្ងៃទី១១ ខែសីហា ឆ្នាំ ២០១១ កម្មករ ឃួន លី បានគេងនៅក្នុងបន្ទប់ដាក់ក្រណាត់។
- ចំពោះករណីឈប់ឥតច្បាប់ និងដេកក្នុងម៉ោងការងារខាងលើ និយោជកបានហៅគាត់ទៅណែនាំ និងព្រមានជាលាយលក្ខណ៍អក្សរដែរ ប៉ុន្តែ កម្មករ ឃួន លី ពុំបានរាងចាលទេ។ ទន្ទឹមនឹងនេះដែរ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ កម្មករ ឃួន លី បានឈ្លោះប្រកែក និងគំរាមកំហែងទៅប្រធានក្រុមទាំងអស់ ស្តីអំពីការដែលកម្មករនិយោជិតបានបោះឆ្នោតទំលាក់រូបគាត់ចេញពីតំណែងលេខាធិការនៃសហជីពសិទ្ធិប្រយោជន៍កម្មករ។ កត្តាទាំងអស់នេះហើយ ដែលធ្វើឱ្យនិយោជកសម្រេចបញ្ឈប់គាត់ពីការងារ។ ភាគីកម្មករនិយោជិតពុំបានបដិសេធទៅនឹងការលើកឡើងរបស់ភាគីនិយោជកទេ។
- ភាគីកម្មករនិយោជិតបានលើកឡើងពីការទាមទារនេះថា ការបញ្ឈប់នេះ គឺដោយសារតែមានការរើសអើងសហជីព ព្រោះថា នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ កម្មករនិយោជិតបានរៀបចំបោះឆ្នោត ដើម្បីជ្រើសរើសថ្នាក់ដឹកនាំសហជីពស្មារតីកម្មករខ្មែរ។ នៅពេលនោះ កម្មករ ឃួន លី បានជាប់ជាប្រធានសហជីពស្មារតីកម្មករខ្មែរ។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ កម្មករនិយោជិតបានជូនដំណឹងពីសមាសភាពនៃថ្នាក់ដឹកនាំសហជីពទៅនិយោជកតែសន្តិសុខក្រុមហ៊ុនពុំទទួលយកលិខិតជូនដំណឹងនេះទេ បន្ទាប់មកទើបពួកគាត់ផ្ញើរលិខិតនេះតាមរយៈប្រៃសណីយ៍វិញ។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកពុំដែលទទួលលិខិតជូនដំណឹងថា គាត់ជាប្រធានសហជីពទេ។

THE ARBITRATION COUNCIL

មូលហេតុដែលគាត់សុំទៅអធិការការងារនេះ គឺដោយសារតែគាត់មានតួនាទីជាតំណាងប្រតិភូបុគ្គលិក ។

- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបង្ហាញថា ពួកគាត់នឹងធ្វើឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។

ចំណុចវិវាទទី២ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទាត់ទៀងចំនួន ១០ (ដប់) ដុល្លារអាមេរិក ក្នុង១(មួយ) ខែ

- ការអនុវត្តរបស់ក្រុមហ៊ុន គឺនិយោជកបានផ្តល់ឱ្យនូវប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ៧ (ប្រាំពីរ) ដុល្លារអាមេរិក ក្នុង១(មួយ) ខែ ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ការដែលនិយោជកផ្តល់ឱ្យនេះមិនមានភាពល្មមនឹងការចំណាយទេ ។ លើសពីនេះទៀត ការផ្តល់នូវឱ្យប្រាក់រង្វាន់ធ្វើការទាត់ទៀងចំនួន១០(ដប់) ដុល្លារអាមេរិកក្នុង១(មួយ)ខែ អាចជួយកុំឱ្យកម្មករនិយោជិតកាត់បន្ថយការឈប់សម្រាកទៀតផង ហើយអាចធ្វើឱ្យកម្មករនិយោជិតខិតខំធ្វើការថែមទៀត ។
- ភាគីនិយោជកបានអះអាងថា ក្រុមហ៊ុនមិនមានលទ្ធភាពផ្តល់ឱ្យកម្មករនិយោជិតចំពោះការទាមទារនេះទេ ហើយកន្លងមក ភាគីទាំងពីរក៏ពុំមានកិច្ចព្រមព្រៀងក្នុងការផ្តល់ជូនប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែដែរ ។

ចំណុចវិវាទទី៣ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកកាត់ប្រាក់រង្វាន់ធ្វើការទាត់ទៀងសមាមាត្រទៅតាមចំនួនថ្ងៃដែលកម្មករនិយោជិតបានឈប់ដោយមានច្បាប់អនុញ្ញាត

- ការអនុវត្តរបស់ក្រុមហ៊ុន បើកម្មករនិយោជិតឈប់មានការអនុញ្ញាត ឬគ្មានការអនុញ្ញាតពីនិយោជកក្តី (ឈប់មានធុរៈ ឬឈប់ឈឺដែលមានសំបុត្រពេទ្យមកបញ្ជាក់) និយោជកនឹងកាត់នូវប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ៧ ដុល្លារអាមេរិកទាំងអស់ ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីការទាមទារថា សុំឱ្យនិយោជកកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់នេះតាមចំនួនថ្ងៃដែលពួកគាត់ឈប់មានធុរៈ ឬឈប់ឈឺដែលមានការអនុញ្ញាតត្រឹមត្រូវពីនិយោជក ។
- ភាគីនិយោជកមិនបានបដិសេធចំពោះការលើកឡើងរបស់ភាគីកម្មករនិយោជិតឡើយ ។

ចំណុចវិវាទទី៤ ៖ កម្មករនិយជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃស្នាក់នៅ និង ប្រាក់សោហ៊ុយធ្វើដំណើរចំនួន ១០ (ដប់) ដុល្លារអាមេរិក ក្នុង ១ (មួយ) ខែ

- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីការទាមទារនេះថា ឥឡូវនេះថ្លៃសោហ៊ុយធ្វើដំណើរមានការឡើងថ្លៃ គឺឡើងពី ៨ ដុល្លារអាមេរិក ដល់ ១១ ដុល្លារអាមេរិក ក្នុងមួយខែ និងពី ១០ ដុល្លារអាមេរិកក្នុងមួយខែ ទៅ ១៣ ដុល្លារអាមេរិក ក្នុងមួយខែ ។
- ភាគីនិយោជកមិនមានលទ្ធភាពផ្តល់បានទេ ព្រោះក្រុមហ៊ុនមិនមានការបញ្ជាទិញច្រើនទេ ។

THE ARBITRATION COUNCIL

ចំណុចវិវាទទី៥ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ប្រចាំខែចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ដល់ប្រធានក្រុម និង ៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតទាំងអស់

- ការអនុវត្តរបស់ក្រុមហ៊ុន គឺនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់កម្មករនិយោជិត ទៅតាមការខិតខំប្រឹងប្រែងរបស់ពួកគាត់។ ជាទូទៅ ប្រធានក្រុមអាចទទួលបានចំនួន ៨ ដុល្លារអាមេរិកក្នុងមួយខែ ចំណែកឯកូនក្រុមអាចទទួលបានចំនួនពី ៣ទៅ ៦ដុល្លារអាមេរិកក្នុងមួយខែ។ ការទទួលប្រាក់រង្វាន់នេះ គឺអាស្រ័យទៅតាមការសហការរវាងប្រធានក្រុម និងកូនក្រុម។
- នៅក្នុងក្រុមហ៊ុនមានប្រធានក្រុមចំនួនសរុបប្រហែល ៥៩ នាក់ ហើយកម្មករនិយោជិត ដែលជាកូនក្រុមសរុបមានចំនួន ១៥០០ នាក់។
- ភាគីកម្មករនិយោជិតបានលើកឡើងថា ការទាមទារនេះ ពុំទាក់ទងទៅនឹងការផ្តល់ជូនប្រាក់រង្វាន់ខាងលើដែលនិយោជកកំពុងតែផ្តល់ជូននេះទេ។ ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនដល់ប្រធានក្រុម និង ៥ ដុល្លារអាមេរិក ក្នុងមួយខែជូនកម្មករនិយោជិត ដែលជាកូនក្រុមទាំងអស់។ មូលហេតុនៃការទាមទារនេះ គឺដើម្បីលើកទឹកចិត្តដល់កម្មករនិយោជិត។
- ភាគីនិយោជកបានបញ្ជាក់ពីជំហរថា និយោជកពុំអាចផ្តល់ជូនតាមការទាមទារនេះទេ។

ចំណុចវិវាទទី៦ ៖ កម្មករនិយោជិតដែលមានផ្ទៃពោះចាប់ពីមួយខែកន្លះឡើងទៅសុំឱ្យនិយោជកអនុញ្ញាតឱ្យទៅពិនិត្យសុខភាពមួយថ្ងៃក្នុងមួយខែ ដោយរក្សាអត្ថប្រយោជន៍ផ្សេងៗ

- នៅសវនាការថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ភាគីទាំងពីរបានព្រមព្រៀងគ្នាថា ភាគីនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតដែលមានផ្ទៃពោះទៅពិនិត្យសុខភាពក្នុងមួយខែចំនួនមួយវេន គឺវេនពេលព្រឹក(៥ម៉ោង)។ *<u>ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនពិចារណាលើចំណុចវិវាទនេះទេ។</u>*

ចំណុចវិវាទទី៧ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកចាក់ចំរៀងនៅម៉ោងធ្វើការ

- តាមការអនុវត្តជាក់ស្តែង និយោជកបានចាក់ចំរៀង ១ ម៉ោង ៣០នាទី នៅពេលព្រឹក និង ១ម៉ោង ៣០នាទី នៅពេលរសៀល ឱ្យដល់កម្មករនិយោជិតស្តាប់នៅពេលកំពុងធ្វើការ។
- ភាគីកម្មករនិយោជិតសុំឱ្យនិយោជកចាក់ចំរៀងបន្ថែមចំនួន៣០នាទីទៀត លើម៉ោងដែលនិយោជកបានផ្តល់ឱ្យ ព្រោះថា នៅពេលដែលកម្មករនិយោជិតបានស្តាប់ចំរៀង ពួកគាត់មានអារម្មណ៍ភ្លឺថ្លា និងចង់ធ្វើការ។
- ភាគីនិយោជកបានបញ្ជាក់ថា មិនអាចចាក់បទចំរៀងលើស ៣ ម៉ោង ក្នុងមួយថ្ងៃទេ។

ចំណុចវិវាទទី៨ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជករៀបចំកម្មវិធីជប់លៀង និងចាប់រង្វាន់ផ្សេងៗ នៅថ្ងៃសិទ្ធិនារី (ថ្ងៃទី៨ ខែមីនា)

- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីការទាមទារថា កម្មករនិយោជិតភាគច្រើន គឺជាស្ត្រីដូចនេះការដែលមាន

កម្មវិធីសម្រាប់ថ្ងៃបុណ្យសិទ្ធិនារីនេះបានបង្កើតនូវភាពរីករាយនៅក្នុងក្រុមហ៊ុន ។

- ភាគីនិយោជកបានបញ្ជាក់ថា រាល់ឆ្នាំនិយោជកបានរៀបចំកម្មវិធីជប់លៀងមុនចូលឆ្នាំប្រពៃណីខ្មែរ និងមានរង្វាន់ចែកជូនដល់កម្មករនិយោជិតគ្រប់ៗគ្នា ។ ដូចនេះ និយោជកមិនមានលទ្ធភាពក្នុងការរៀបចំកម្មវិធីជប់លៀង និងចាប់រង្វាន់ផ្សេងៗនៅថ្ងៃសិទ្ធិនារី( ថ្ងៃទី៨ ខែមីនា) បានទេ ។

**ចំណុចវិវាទទី៩ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជករៀបចំទៅពិនិត្យសុខភាពជាពិសេសក្នុងមួយឆ្នាំ ២ ដង**

- ភាគីកម្មករនិយោជិតបានលើកឡើងពីមូលហេតុនៃការទាមទារនេះថា នៅពេលធ្វើការ កម្មករនិយោជិតប្រឈមទៅនឹងកំទេចក្រណាត់ដែលអាចហុយចូលច្រមុះ និងម៉្យាងទៀត ក្រណាត់ទាំងនោះសុទ្ធតែមានជាតិគីមីដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខភាព ។ ដូចនេះហើយ ការពិនិត្យសុខភាពនេះមានសារសំខាន់ណាស់ចំពោះកម្មករនិយោជិត ។ ចំពោះការពិនិត្យសុខភាពនេះពួកគាត់ទាមទារឱ្យមានការពិនិត្យ ដូចជាពិនិត្យសួត ថ្លើម បេះដូង និង តំរងនោម ។ ភាគីកម្មករនិយោជិតមិនបានលើកឡើងថា ធ្លាប់មានកម្មករណា កើតមានជម្ងឺពីការបំពេញការងាររបស់ខ្លួននោះទេ ។
- ភាគីនិយោជកបញ្ជាក់ថា នៅពេលដែលកម្មករនិយោជិតចូលធ្វើការដំបូង គឺមានការពិនិត្យសុខភាពរួចហើយ ហើយនិយោជកជាអ្នកចេញសោហ៊ុយក្នុងការពិនិត្យនេះ ។ មួយវិញទៀត ក្រុមហ៊ុនជាប្រភេទក្រុមហ៊ុនកាត់ដេរខោអាវកីឡា ហើយមិនមានសារជាតិគីមី ដែលអាចប៉ះពាល់ដល់សុខភាពកម្មករនិយោជិតទេ ។

**ហេតុផលនៃសេចក្តីសម្រេច**

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារសុំឱ្យនិយោជកទទួលលោក ឃួន លី ដែលជាថ្នាក់ដឹកនាំសហជីពស្មារតីកម្មករខ្មែរចូលធ្វើការវិញជាធម្មតា និងរក្សាអត្ថប្រយោជន៍ផ្សេងៗនៅដដែល**

នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើនិយោជកត្រូវទទួលយកកម្មករ ឃួន លី ឱ្យចូលធ្វើការងារវិញដែរ ឬទេ?

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារចែងថា "*រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួនអាចធ្វើបាន លុះត្រាណាតែមានការយល់ព្រមពីអធិការការងារ ។ វិធានការការពារទាំងឡាយដូចគ្នានេះត្រូវអនុវត្តចំពោះអតីតប្រតិភូបុគ្គលិកក្រោយពេលបញ្ចប់អាណត្តិរបស់ខ្លួនបីខែ និងក្នុងរយៈពេលបីខែចំពោះអតីតបេក្ខជនមិនជាប់ឆ្នោតក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត ។ រាល់គំរោងផ្លាស់ប្តូរឬផ្ទេរការងាររបស់ប្រតិភូដែលនាំអោយមានការបាត់បង់តំណែងក្នុងអាណត្តិ ក៏ត្រូវដាក់ឱ្យស្ថិតក្រោមនីតិវិធីនេះដែរ ។ អធិការការងារដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសំរេចរបស់ខ្លួនដល់និយោជកដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់ ក៏ដូចជាដល់អង្គការសហជីពដែលគ្រប់គ្រងកម្មករនិយោជិតនោះក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយទទួលពាក្យបណ្តឹង ។ បន្ទាប់ពីបានទទួលសេចក្តីសំរេចនោះ និយោជក កម្មករនិយោជិតដែលត្រូវបញ្ឈប់ ឬអង្គការសហជីពរបស់កម្មករនិយោជិតនោះ មានរយៈពេលពីរខែ ដើម្បីធ្វើឧធ្ធរណ៍ទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចបដិសេធចោល ឬកែ*

*សំរួលសេចក្តីសំរេចរបស់អធិការការងារ ។ បើគ្មានការជូនដំណឹងអំពីសេចក្តីសំរេចរបស់អធិការការងារ ក្នុងរយៈពេល ដែលបានកំណត់ឱ្យទេ ឬបើគ្មានការជូនដំណឹងអំពីសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ក្នុង រយៈពេលពីរខែ បន្ទាប់ពីបានទទួលឧបាស្រ័យតាមឋានានុក្រមនោះ ពាក្យបណ្តឹង និងឧបាស្រ័យនោះ ត្រូវចាត់ទុកថា បានបដិសេធចោល " ។*

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើយោងតាមមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារខាងលើ គឺអធិការការងារត្រូវឆ្លើយតបក្នុងរយៈពេលមួយខែបន្ទាប់ពីគាត់ទទួលបានលិខិតស្នើសុំបញ្ឈប់លោក ឃួន លី ពីនិយោជក ។ បើអធិការការងារពុំបានឆ្លើយតបក្នុងរយៈមួយខែទេ មានន័យថា អធិការការងារបដិសេធទៅនឹងសំណើរបញ្ឈប់នេះ ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ៧៦/០៤*-អ៊ឹម វ៉េ *(កំពង់ឆ្នាំង)* ហេតុផលចំណុចវិវាទទី៣) ។

តាមរយៈអង្គហេតុ និយោជកបានព្យួរកម្មករ ឃួន លី នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ បន្ទាប់មកនៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១១ និយោជកបានធ្វើលិខិតស្នើសុំបញ្ឈប់កម្មករ ឃួន លី ជាប្រតិភូបុគ្គលិកទៅអធិការការងារ ។ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១២ អធិការការងារបានចេញលិខិតឆ្លើយតបយល់ព្រមទាក់ទងទៅនឹងការស្នើសុំបញ្ឈប់នេះ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លិខិតអនុញ្ញាតឱ្យបញ្ឈប់កម្មករ ឃួន លី ដែលចេញដោយអធិការការងារពុំបានចេញក្នុងរយៈពេលមួយខែតាមកាលកំណត់របស់មាត្រា ២៩៣ ទេ ពោលអធិការការងារបានចេញយឺតរយៈពេល ១៧ ថ្ងៃ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្មត់ថា អធិការការងារបានបដិសេធនូវការបញ្ឈប់នេះហើយ ថ្វីត្បិតតែមានលិខិតយល់ព្រមពីអធិការការងារក៏ដោយ ។ ដូចនេះ និយោជកត្រូវទទួលយកកម្មករ ឃួន លី ចូលធ្វើការងារវិញ ។

យោងតាមមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារបានបញ្ជាក់យ៉ាងច្បាស់ថា បន្ទាប់ពីទទួលការបានសេចក្តីសម្រេចបញ្ឈប់ពីអធិការការងារ ដូចនេះ និយោជក ឬកម្មករនិយោជិតដែលត្រូវបញ្ឈប់ ឬអង្គការសហជីពរបស់កម្មករនិយោជិតនោះមានរយៈពេលពីរខែ ដើម្បីធ្វើឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារក្នុងការដែលជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អធិការការងារ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកអាចធ្វើឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួង ដើម្បីជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អធិការការងារ ។ បើក្នុងករណីនិយោជកធ្វើឧបាស្រ័យទៅរដ្ឋមន្ត្រី និយោជកអាចព្យួរការងាររបស់កម្មករ ឃួន លី បន្តទៀតរហូតដល់រដ្ឋមន្ត្រីក្រសួងឆ្លើយតបយល់ព្រម ឬបដិសេធទៅនឹងការស្នើសុំបញ្ឈប់នេះ ពោលគឺមានរយៈពេលដល់ទៅពីរខែទៀតច្រើនបំផុត ដែលជាពេលរដ្ឋមន្ត្រីក្រសួងការងារត្រូវធ្វើការឆ្លើយតប ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យនិយោជកទទួលយកកម្មករ ឃួន លី ចូលធ្វើការងារវិញបន្ទាប់ពីសេចក្តីបង្គាប់អាជ្ញាកណ្តាលចូលជាធរមាន លើកលែងតែនិយោជកបន្តធ្វើឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួង ។

**ចំណុចវិវាទទី២ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០(ដប់) ដុល្លារ អាមេរិក ក្នុង១ ខែ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាការទាមទារនេះដូចតទៅ ៖

THE ARBITRATION COUNCIL

តាមរយៈចំណុចទី១ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ កប/ស.ជ.ណ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ចែងថា *"កម្មករនិយោជិត ដែលបានមកធ្វើការទៀងទាត់ តាមចំនួនថ្ងៃធ្វើការក្នុងខែនីមួយៗ ត្រូវទទួលបានប្រាក់រង្វាន់យ៉ាងតិចចំនួន ៧ (ប្រាំពីរ) ដុល្លារអាមេរិកក្នុងមួយខែ"* ។

យោងតាមសេចក្តីជូនដំណឹងនេះ និយោជកត្រូវផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ជូនកម្មករនិយោជិតចំនួន ៧ ដុល្លារអាមេរិក ក្នុងមួយខែ បើកម្មករនិយោជិតមកធ្វើការទៀងទាត់ តាមចំនួនថ្ងៃធ្វើការក្នុងខែនីមួយៗ ។

តាមរយៈអង្គហេតុ និយោជកបានផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់នេះ ចំនួន ៧ ដុល្លារអាមេរិក ក្នុងមួយខែ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតឱ្យផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែនេះ មានកលក្ខណៈលើសពីអ្វីដែលច្បាប់បានកំណត់ ដូច្នេះ ការទាមទារនេះ គឺជាការទាមទារពាក់ព័ន្ធនឹងផលប្រយោជន៍ ពោលគឺវិវាទអំពីផលប្រយោជន៍ ។

ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ ។ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារនោះ មកជាសហជីព ដែលមិនមានភាពជាតំណាងបំផុតនៅក្នុងរោងចក្រ (*សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ ៤២/០៩-វីវីរីច តិចស្តាយ ហេតុផលចំណុចវិវាទទី២ និងលេខ ៦២/១០-ចុង យ៉ូវ ហេតុផលចំណុចវិវាទទី៥*) ។

ក្នុងករណីនេះ សហជីពស្មារតីកម្មករខ្មែរពុំមានបញ្ជិកាសហជីពនៅឡើយ ដូចនេះសហជីពនេះរឹតតែពុំមានភាពជាតំណាងបំផុតទៅទៀត ។ មានកម្មករនិយោជិតចំនួន ២៥៨ នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ១៥០០ នាក់ ដែលបានពឹងពាក់មកសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ ក្នុងការនាំបណ្តឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពផ្តល់គុណវុឌ្ឍន៍ផ្នែកច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ ក្នុងការនាំសំណុំរឿងវិវាទអំពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។ ដើម្បីទទួលបានភាពជាតំណាងបំផុតនេះ មាត្រា ២៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា *"សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ"* ។

បន្ថែមពីនេះ ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលដោះស្រាយវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍ នឹងមកជំនួសអនុសញ្ញារួម សម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីចរចាបង្កើតអនុសញ្ញារួមមួយដើម្បីជំនួសសេចក្តីបង្គាប់នេះ"* ។

ផ្អែកលើប្រការ ៤៣ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបង្គាប់ដែលដោះស្រាយវិវាទអំពីផលប្រយោជន៍ សេចក្តីបង្គាប់នោះនឹងក្លាយជាអនុសញ្ញារួមរយៈពេលមួយឆ្នាំ ។ ជាទូទៅ អនុសញ្ញារួមត្រូវបានអនុវត្តចំពោះកម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ ហើយសិទ្ធិក្នុងការ

ធ្វើកូដកម្មមិនអាចអនុវត្តឡើងសម្រាប់សើរើឡើងវិញនូវអនុសញ្ញារួម នៅពេលដែលអនុសញ្ញារួមនោះមិនទាន់ផុតកំណត់នោះទេ (*សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ ១៩២/០៨-វិលសិន ហេតុផលចំណុចវិវាទទី២*) ។

ដោយសារដើមបណ្តឹងក្នុងសំណុំរឿងនេះ មិនមែនជាសហជីពដែលមានភាពជាតំណាងបំផុត ដូចនេះ ពួកគាត់ពុំទាន់មានសិទ្ធិស្របច្បាប់ ក្នុងការនាំវិវាទពីផលប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធ្វើការដោះស្រាយទេ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទារឱ្យនិយោជក ផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ (ដប់)ដុល្លារអាមេរិក ក្នុងមួយខែ ។

**ចំណុចវិវាទទី៣ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកកាត់ប្រាក់រង្វាន់ធ្វើការទាត់ទៀងសមាមាត្រទៅតាមចំនួនថ្ងៃដែលកម្មករនិយោជិតបានឈប់ដោយមានការច្បាប់**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់រង្វាន់ធ្វើការទៀងទាត់សមាមាត្រទៅនឹងចំនួនថ្ងៃឈប់មានធុរៈ ឬមានជំងឺ ដោយមានច្បាប់អនុញ្ញាតពីនិយោជកដែរ ឬទេ?

ចំណុចទី១ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ តម្រូវឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ឱ្យកម្មករនិយោជិត ដែលបានមកធ្វើការទៀងទាត់ តាមចំនួនថ្ងៃធ្វើការក្នុងខែនីមួយៗ ប៉ុន្តែសេចក្តីជូនដំណឹងនេះមិនមានចែងច្បាស់អំពីប្រាក់រង្វាន់ការងារទៀងទាត់ដែលកម្មករនិយោជិតត្រូវទទួលបាននៅពេលអវត្តមានមានច្បាប់ឡើយ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាពាក្យគន្លឹះ "ចំនួនថ្ងៃធ្វើការក្នុងខែនីមួយៗ" នៃសេចក្តីជូនដំណឹងលេខ ០៤១ ដូចខាងក្រោម ៖

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ (១១២/១១-យ៉ុងវ៉ាទី១ ចំណុចវិវាទទី៣ និង លេខ ០៣/១៤-ខេមវែល ចំណុចវិវាទទី៦) ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា "*ចំនួនថ្ងៃធ្វើការទៀងទាត់ក្នុងខែនីមួយៗ គឺសំដៅចំនួនថ្ងៃក្នុងខែនីមួយៗ ដែលនិយោជកតម្រូវឱ្យកម្មករនិយោជិតមកធ្វើការ ឬកម្មករនិយោជិតមានកាតព្វកិច្ចតាមផ្លូវច្បាប់ត្រូវផ្តល់សេវាកម្មជូនដល់និយោជក ។ ផ្អែកតាមច្បាប់ និងការអនុវត្តសព្វថ្ងៃរបស់សហគ្រាសគ្រឹះស្ថាន នៅកម្ពុជាពាក្យ "ថ្ងៃធ្វើការនៃខែនីមួយៗ" អាចជា ៖*

*(១) ថ្ងៃដែលធ្វើការពេញ (ករណីគ្មានថ្ងៃឈប់សម្រាកបុណ្យជាតិ និងបុណ្យផ្សេងៗ ដែលច្បាប់កំណត់ មានន័យថា ចំនួន ២៦ ថ្ងៃ ក្នុងមួយខែ ឬ ២១-២២ ថ្ងៃ ក្នុងមួយខែអាស្រ័យតាមការអនុវត្តរបស់ក្រុមហ៊ុននីមួយៗ) នៃខែនីមួយៗ ។*

*(២) ថ្ងៃដែលធ្វើការមិនពេញ (ករណីមានថ្ងៃឈប់សម្រាកបុណ្យជាតិ និងបុណ្យផ្សេងៗ ដែលច្បាប់កំណត់ មានន័យថា ចំនួនថ្ងៃធ្វើការក្នុងខែ តិចជាងចំនួន ២៦ ថ្ងៃ ក្នុងមួយខែ ឬ ២១-២២ថ្ងៃ ក្នុងមួយខែ អាស្រ័យតាមចំនួនថ្ងៃឈប់សម្រាកបុណ្យជាតិ និងបុណ្យផ្សេងៗ ដែលច្បាប់កំណត់ និងការអនុវត្តរបស់ក្រុមហ៊ុននីមួយៗ) ។*

*(៣) ថ្ងៃដែលធ្វើការមិនពេញ (ករណីមានការអនុញ្ញាតច្បាប់ត្រឹមត្រូវដោយនិយោជក មានន័យថា ចំនួនថ្ងៃធ្វើការក្នុងខែ តិចជាងចំនួន ២៦ ថ្ងៃ ក្នុងមួយខែ ឬ២១-២២ថ្ងៃក្នុងមួយខែ អាស្រ័យតាមការអនុវត្តរបស់ក្រុមហ៊ុន*

THE ARBITRATION COUNCIL

*នីមួយៗ និងចំនួនថ្ងៃដែលនិយោជកអនុញ្ញាតច្បាប់ឱ្យកម្មករនិយោជិត)* "។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ៦៤/១១-អ៊ីម វ៉េ ហេតុផលចំណុចវិវាទទី១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរថា តើកម្មករនិយោជិតគួរទទួលបានប្រាក់រង្វាន់ការងារទៀងទាត់ក្នុងករណីណាខ្លះ និងចំនួនប៉ុន្មាន?

មាត្រា ១០៣ នៃច្បាប់ស្តីពីការងារ ចែងថា "*ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ ៖*

*- ប្រាក់ដែលបើកជារង្វាន់*

*-...*"។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រាក់រង្វាន់ធ្វើការទៀងទាត់ដែលកំណត់ដោយសេចក្តីជូនដំណឹងលេខ ០៤១/១១ កប/ស.ជ.ណ គឺជាប្រាក់ដែលបើកជារង្វាន់ដោយនិយោជកឱ្យកម្មករនិយោជិត។ ហេតុនេះ ប្រាក់រង្វាន់ធ្វើការទៀងទាត់ ត្រូវបានចាត់ទុកថា ជាប្រភេទមួយនៃប្រាក់ឈ្នួល។

មាត្រា ៧១ កថាខ័ណ្ឌទី ៦ នៃច្បាប់ស្តីពីការងារចែងថា "*កិច្ចសន្យាការងារត្រូវព្យួរដោយមូលហេតុដូចខាងក្រោម ៖...*

*៣-អវត្តមាននៃកម្មករនិយោជិត ក្នុងករណីមានជម្ងឺដែលមានគ្រូពេទ្យផ្លូវការបានបញ្ជាក់ត្រឹមត្រូវ...*"។

*៦-អវត្តមាននៃកម្មករនិយោជិត ដែលនិយោជកបានអនុញ្ញាតតាមច្បាប់ តាមការព្រមព្រៀងរួម ឬការយល់ព្រមរៀងរួម..*"។

មាត្រា៧២ កថាខ័ណ្ឌទី១នៃច្បាប់ស្តីពីការងារចែងថា "*ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់តែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត ...*"។

ផ្អែកតាមមាត្រា៧១ កថាខ័ណ្ឌទី ៣ និង ៦ និងមាត្រា៧២ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំពោះថ្ងៃដែលធ្វើការមិនពេញក្នុងករណីទី ៣ ខាងលើ ការឈប់សម្រាកដោយមានច្បាប់អនុញ្ញាតពីនិយោជក គឺកើតចេញពីការស្នើសុំរបស់កម្មករនិយោជិត និងការព្រមព្រៀងពីនិយោជក និងព្រមទាំងអវត្តមាននៅពេលដែលកម្មករនិយោជិតមានជំងឺ ប៉ុន្តែមានសំបុត្រពេទ្យផ្លូវការមកបញ្ជាក់។ ដូចនេះ ការឈប់សម្រាកនេះ គឺជាការព្យួរកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិត ហើយដែលនិយោជកមិនមានកាតព្វកិច្ចបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិតចំពោះថ្ងៃដែលឈប់សម្រាកនោះទេ។ មានន័យថា និយោជកក៏មិនមានកាតព្វកិច្ចផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ឱ្យកម្មករនិយោជិតចំពោះថ្ងៃ ដែលឈប់សម្រាកនោះដែរ។ ហេតុនេះ និយោជកមិនមានសិទ្ធិកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់របស់កម្មករនិយោជិតទាំងអស់ទេ គឺមានសិទ្ធិកាត់តែសមាមាត្រនៃថ្ងៃ ដែលកម្មករនិយោជិតឈប់សម្រាកនោះប៉ុណ្ណោះ។

THE ARBITRATION COUNCIL

នៅក្នុងសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់តែត្រឹមសមាមាត្រនៃចំនួនថ្ងៃ ដែលកម្មករនិយោជិតឈប់ដោយមានច្បាប់អនុញ្ញាតពីនិយោជក... ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៣៦/១១-ខេមបូហ៊ែនសាំ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និងលេខ ១៥៤/១១-ប៊ី & អិន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី ៧(២))* ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ សមាមាត្រតាមចំនួនថ្ងៃ ដែលកម្មករនិយោជិតឈប់មានធុរៈ ឬមានជំងឺដោយមានច្បាប់អនុញ្ញាតពីនិយោជក ។

**ចំណុចវិវាទទី៤ ៖ កម្មករនិយជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃស្នាក់នៅ និងប្រាក់សោហ៊ុយធ្វើដំណើរចំនួន ១០ (ដប់) ដុល្លារអាមេរិក ក្នុងមួយខែ**

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ១០ (ដប់) ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត សម្រាប់សោហ៊ុយថ្លៃឡាន និងថ្លៃស្នាក់នៅ ពីព្រោះថា បច្ចុប្បន្ននេះសោហ៊ុយឡានសម្រាប់ធ្វើដំណើរបានឡើងថ្លៃ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ចំនួន ១០ (ដប់) ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់សោហ៊ុយធ្វើដំណើរនិងសម្រាប់ថ្លៃស្នាក់នៅគឺ មិនមានចែងនៅក្នុងច្បាប់ស្តីពីការងារទេ ហើយភាគីក៏ពុំធ្លាប់មានកិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយដែលចែងអំពីការទាមទារនេះដែរ។ ដូច្នេះ ការទាមទារនេះ គឺជាការទាមទារដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពោលជាវិវាទអំពីផលប្រយោជន៍។ *(សូមមើលចំណុចវិវាទអំពីប្រយោជន៍ នូវចំណុចវិវាទទី២ ខាងលើ)* ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ចំនួន ១០ (ដប់) ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់សោហ៊ុយធ្វើដំណើរ និងសម្រាប់ថ្លៃ ឱ្យស្នាក់នៅ។

**ចំណុចវិវាទទី៥ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ប្រចាំខែចំនួន ១០(ដប់) ដុល្លារអាមេរិក ក្នុងមួយខែ ដល់ប្រធានក្រុម និង ៥ (ប្រាំ) ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតទាំងអស់**

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ប្រចាំខែចំនួន ១០ (ដប់)ដុល្លារអាមេរិក ក្នុងមួយខែ ដល់ប្រធានក្រុម និង ៥ (ប្រាំ)ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតដែលជាកូនក្រុមទាំងអស់ ពីព្រោះថា ការផ្តល់នូវប្រាក់រង្វាន់គ្រប់ៗបានជំរុញឱ្យកម្មករនិយោជិតទាំងអស់ខិតខំឱ្យបានល្អទាំងអស់គ្នា។ ចំណែកឯភាគីនិយោជកវិញបានបញ្ជាក់ថា និយោជកពុំអាចផ្តល់ជូនបានទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ចំនួន ១០ (ដប់) ដុល្លារអាមេរិក ក្នុងមួយខែ ដល់ប្រធានក្រុម និង ៥ (ប្រាំ) ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត ដែលជាកូនក្រុមទាំងអស់ មិនមានចែងនៅក្នុងច្បាប់ស្តីពីការងារទេ ហើយភាគីក៏ពុំធ្លាប់មានកិច្ច ឱ្យព្រមព្រៀង ឬអនុសញ្ញារួមណាមួយ ដែលចែងអំពីការទាមទារនេះដែរ។ ដូច្នេះ ការទាមទារនេះ គឺជាការទាមទារ ដែល

ARBITRATION COUNCIL

ពាក់ព័ន្ធនឹងផលប្រយោជន៍ ពោលជាវិវាទអំពីផលប្រយោជន៍។ (*សូមមើលចំណុចវិវាទអំពីប្រយោជន៍នូវចំណុចវិវាទទី២ ខាងលើ*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ចំនួន ១០ (ដប់)ដុល្លារអាមេរិក ក្នុងមួយខែ ដល់ប្រធានក្រុម និង ៥ (ប្រាំ)ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតទាំងអស់។

**ចំណុចវិវាទទី៧ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកចាក់ចំរៀងនៅម៉ោងធ្វើការ**

កម្មករនិយោជិតទាមទារឱ្យនិយោជកចាក់ចំរៀងនៅម៉ោងធ្វើការដែលជាធម្មតា និយោជកបានចាក់ ១ម៉ោង ៣០នាទី នៅពេលព្រឹក និង ១ ម៉ោង ៣០ នាទី នៅពេលល្ងាច។ តែក្នុងករណីនេះ កម្មករនិយោជិតទាមទារឱ្យនិយោជកចាក់ចំរៀងបន្ថែមនូវម៉ោងធ្វើការចំនួន ៣០នាទីទៀត នៅពេលព្រឹក និង ៣០នាទីទៀត នៅពេលល្ងាច។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកចាក់ចំរៀងបន្ថែមនូវម៉ោងធ្វើការចំនួន ៣០នាទីទៀត នៅពេលព្រឹក និង ៣០នាទីទៀត នៅពេលល្ងាច គឺមិនមានចែងនៅក្នុងច្បាប់ស្តីពីការងារទេ ហើយភាគីក៏ពុំធ្លាប់មានកិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយដែលចែងអំពីការទាមទារនេះដែរ។ ដូច្នេះ ការទាមទារនេះគឺជាការទាមទារដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពោលជាវិវាទអំពីផលប្រយោជន៍។ (*សូមមើលចំណុចវិវាទអំពីប្រយោជន៍នូវចំណុចវិវាទទី២ ខាងលើ*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកចាក់ចំរៀងនៅម៉ោងធ្វើការ។

**ចំណុចវិវាទទី៨ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជករៀបចំកម្មវិធីជប់លៀង និងចាប់រង្វាន់ផ្សេងៗ នៅថ្ងៃសិទ្ធិនារី (ថ្ងៃទី៨ ខែមីនា)**

កម្មករនិយោជិតទាមទារឱ្យនិយោជករៀបចំកម្មវិធីជប់លៀង និងចាប់រង្វាន់ផ្សេងៗ នៅថ្ងៃសិទ្ធិនារី នាថ្ងៃទី ៨ ខែមីនា ព្រោះថា ការធ្វើបែបនេះ គឺបង្កើតឱ្យមានភាពរីករាយនៅក្នុងក្រុមហ៊ុន។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជករៀបចំកម្មវិធីជប់លៀង និងចាប់រង្វាន់ផ្សេងៗនៅថ្ងៃសិទ្ធិនារី (ថ្ងៃទី៨ ខែមីនា) គឺ មិនមានចែងនៅក្នុងច្បាប់ស្តីពីការងារទេ ហើយភាគីក៏ពុំធ្លាប់មានកិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយ ដែលចែងអំពីការទាមទារនេះដែរ។ ដូច្នេះ ការទាមទារនេះ គឺជាការទាមទារ ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ពោល គឺវិវាទនេះជាវិវាទអំពីផលប្រយោជន៍។ (*សូមមើលចំណុចវិវាទអំពីប្រយោជន៍នូវចំណុចវិវាទទី២ ខាងលើ*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជករៀបចំកម្មវិធីជប់លៀង និងចាប់រង្វាន់ផ្សេងៗ នៅថ្ងៃសិទ្ធិនារី (ថ្ងៃទី៨ ខែមីនា) ។

THE ARBITRATION COUNCIL

ចំណុចវិវាទទី៩ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជករៀបចំទៅពិនិត្យសុខភាពជាពិសេសក្នុងមួយឆ្នាំ ២ដង

តាមរយៈអង្គហេតុ ភាគីកម្មករនិយោជិត និងនិយោជក ពុំមានវិវាទទាក់ទងទៅនឹងការសុំពិនិត្យសុខភាពមុននឹងចាប់ផ្តើមចូលធ្វើការទេ។ ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានទាមទារឱ្យនិយោជកទទួលខុសត្រូវលើសោហ៊ុយពិនិត្យសុខភាពជាពិសេសនេះមួយឆ្នាំ ចំនួន ២ ដង។ ការពិនិត្យនេះមានដូចជា ពិនិត្យទៅលើ ថ្លើម សួត បេះដូង និងតំរងនោម។ តាមរយៈអង្គហេតុ ភាគីនិយោជកបានបង្ហាញថា ការងារដែលកម្មករនិយោជិតកំពុងធ្វើរាល់ថ្ងៃនេះ ពុំមានប៉ះពាល់ទៅនឹងសុខភាពរបស់កម្មករនិយោជិតទេ ហើយកន្លងមកភាគីទាំងពីរក៏ពុំមានកិច្ចព្រមព្រៀងណាមួយ ដែលតម្រូវឱ្យនិយោជកជាអ្នកទទួលខុសត្រូវលើសោហ៊ុយពិនិត្យសុខភាពជាពិសេសនេះដែរ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនេះ គឺជាការទាមទារលើសពីអ្វីដែលច្បាប់ផ្តល់ជូនព្រោះថា ពុំមានច្បាប់ស្តីពីការងារ ឬបទប្បញ្ញត្តិណាមួយ ដែលចែងតម្រូវឱ្យនិយោជកជាអ្នកទទួលខុសត្រូវលើការពិនិត្យសុខភាពជាពិសេសចំនួន ២ ដង ក្នុងមួយឆ្នាំទេ ដូចនេះ វាគឺជាវិវាទអំពីផលប្រយោជន៍។ (*សូមមើលចំណុចវិវាទអំពីប្រយោជន៍ នូវចំណុចវិវាទទី២ ខាងលើ*)។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជករៀបចំការពិនិត្យសុខភាពជាពិសេសដល់កម្មករនិយោជិតមួយឆ្នាំពីរដង។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

បង្គាប់ឱ្យនិយោជកទទួលយកកម្មករ ឃួន លី ចូលធ្វើការងារវិញបន្ទាប់ពីសេចក្តីបង្គាប់អាជ្ញាកណ្តាលចូលជាធរមាន លើកលែងតែនិយោជកបន្តឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

**ចំណុចវិវាទទី ២ ៖**

បដិសេធពិចារណាការទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០(ដប់) ដុល្លារអាមេរិកក្នុងមួយខែ។

**ចំណុចវិវាទទី ៣ ៖**

បង្គាប់ឱ្យនិយោជកកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់សមាមាត្រតាមចំនួនថ្ងៃ ដែលកម្មករនិយោជិតឈប់មានធុរៈ ឬមានជំងឺដោយមានច្បាប់អនុញ្ញាតពីនិយោជក។

**ចំណុចវិវាទទី ៤ ៖**

បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ចំនួន១០ (ដប់) ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់សោហ៊ុយធ្វើដំណើរ និងសម្រាប់ថ្លៃស្នាក់នៅ។

THE ARBITRATION COUNCIL

ចំណុចវិវាទទី ៥ ៖

បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ចំនួន ១០ (ដប់) ដុល្លារ អាមេរិកក្នុងមួយខែ ដល់ប្រធានក្រុម និង ៥ (ប្រាំ)ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិតទាំងអស់ ។

ចំណុចវិវាទទី ៧ ៖

បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកចាក់ចំរៀងនៅម៉ោងធ្វើការ ។

ចំណុចវិវាទទី ៨ ៖

បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជករៀបចំកម្មវិធីជប់លៀង និងចាប់រង្វាន់ផ្សេងៗ នៅថ្ងៃសិទ្ធិនារី( ថ្ងៃទី៨ ខែមីនា) ។

ចំណុចវិវាទទី ៩ ៖

បដិសេធពិចារណាការទាមទារឱ្យនិយោជករៀបចំការពិនិត្យសុខភាពជាពិសេសដល់កម្មករនិយោជិតមួយឆ្នាំពីរដង ។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **អាំង អេងថុង**

ហត្ថលេខា: ----------------------------------------

THE ARBITRATION COUNCIL

## យោបល់ជំទាស់ទៅសេចក្តីសម្រេចនៃសំណុំរឿង អល ស៊ូបតើ អ៊ិនធើប្រាយ ដោយអាជ្ញាកណ្តាល អ៊ីង សុទ្ធី ដែលជ្រើសរើសដោយភាគីនិយោជក

ប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចែងថា *"ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រារាល់សេចក្តីសម្រេចរបស់ខ្លួន ក្នុងសេចក្តីបង្គាប់មួយ ដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្តាលទាំង ០៣ រូប ។ ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់មិនឯកភាពនឹងសេចក្តីសម្រេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយក្នុងសេចក្តីបង្គាប់នោះ "* ។

យោងតាមប្រការនេះ ខ្ញុំអាជ្ញាកណ្តាល **អ៊ីង សុទ្ធី** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងហេតុផលនៃសេចក្តីសម្រេចនៃសេចក្តីបង្គាប់លេខ **២៨/១២ - អល ស៊ូបតើ អ៊ិនធើប្រាយ** ចំណុចវិវាទទី៣ ដែលបង្គាប់ឱ្យនិយោជកកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់សមាមាត្រតាមចំនួនថ្ងៃ ដែលកម្មករនិយោជិតឈប់មានធុរៈ ឬមានជំងឺដោយមានច្បាប់អនុញ្ញាតពីនិយោជក ។ ខ្ញុំសូមបញ្ជាក់ អំពីមូលហេតុនៃការជំទាស់ ដូចមានក្នុងសេចក្តីអត្ថាធិប្បាយខាងក្រោមនេះ ៖

### <u>I-ការពន្យល់ពាក្យ ៖</u>

**១-រង្វាន់ bonus**-prime " (នាម )-របស់ដែលថែមឱ្យដោយឡែកផ្សេង លើសពីកំណត់ដែលត្រូវបាន, របស់ជាបំណាច់ដែលថែមឱ្យ ព្រោះគាប់ចិត្ត ឬដើម្បីបំពេញចិត្ត ៖ ឱ្យរង្វាន់, ទទួលប្រាក់រង្វាន់ ។ រង្វាន់ខាន់ខៅ រង្វាន់ និងទ្រនាប់របស់ដែលឱ្យដោយឡែកផ្សេង ក្រៅពីទ្រនាប់ ។ (ទំព័រ ៩៧០ បន្ទាត់ទី១២ វចនានុក្រម ជួន ណាត ) ។

២-ទ្រនាប់ ៖ រង្វាន់គ្រូមើលជម្ងឺ,រៀបទ្រនាប់គ្រូ,ជូនទ្រនាប់គ្រូ (ទំព័រ ៤៦៣ បន្ទាត់ទី ២ វចនានុក្រមជួនណាត ) ។

**៣-primes (n)(Dt. trav.)** -sommes versees par l'employeur au salairié en sur du salaire normal, soit á titre de remboursement de frais, soit pour encourager la productivité, tenir compte de certaines difficultés particuliéres du travail,ou recompenser l'ancienneté. **[livre, Lexique des termes juridiques 12 éme édition Dalloz 1999 page 413]**

### <u>II-ការបកស្រាយ ៖</u>

ពាក្យថា រង្វាន់ ជារបស់ដែលគេឱ្យសម្រាប់ជាការលើកទឹកចិត្ត ដោយមានភ្ជាប់នូវលក្ខខណ្ឌ។ ដូច្នេះ អ្នកត្រូវទទួលបានរង្វាន់ លុះត្រាតែអ្នកបានបំពេញនូវលក្ខខណ្ឌជាក់លាក់ ឬក៏លក្ខខណ្ឌមានកម្រិតតាមថ្នាក់ ហើយត្រូវបានបំពេញលក្ខខណ្ឌតាមកម្រិតនោះ ។

ជាទូទៅ ក៏ដូចជាគោលការណ៍សម្រាប់ការអនុវត្ត ការផ្តល់រង្វាន់ តើអ្នកណាជាអ្នកមានសិទ្ធិដាក់ ឬដកចេញនូវលក្ខខណ្ឌសម្រាប់ការទទួលរង្វាន់នេះ ? ចម្លើយ គឺ ម្ចាស់រង្វាន់។

ដូច្នេះ សម្រាប់វិស័យការងារវិញ ម្ចាស់រង្វាន់ គឺ និយោជក ចំណែកឯអ្នកត្រូវបំពេញនូវលក្ខខណ្ឌនេះវិញ គឺ កម្មករនិយោជិត។

ឧទាហរណ៍ ៖

ក/១-ចូរអ្នករាប់លេខឱ្យដល់លេខ ១០០០ ខ្ញុំនឹងឱ្យប្រាក់រង្វាន់ ១០០ ដុល្លារ។ ប៉ុន្តែ អ្នករាប់លេខបានត្រឹមតែលេខ ៩០០ អ្នកសុំទៅម្ចាស់រង្វាន់ថា អ្នកហត់ណាស់មិនអាចរាប់គ្រប់ ១០០០ ទេ ម្ចាស់រង្វាន់ក៏អនុញ្ញាតឱ្យអ្នកឈប់រាប់ បន្ទាប់មកអ្នកក៏ធ្វើសំណើមួយសុំឱ្យម្ចាស់រង្វាន់អង្គុំប្រាក់រង្វាន់ ១០០ ដុល្លារ នោះ ចែកមកឱ្យខ្លួន តើអ្នកណាជាអ្នកមានសិទ្ធិសម្រេចក្នុងការអង្គុំប្រាក់រង្វាន់ ១០០ ដុល្លារនេះ នៅពេលដែលអ្នកមិនអាចរាប់គ្រប់ចំនួនតាមលក្ខខណ្ឌ ដែលម្ចាស់រង្វាន់បានកំណត់ឱ្យនោះ? ចម្លើយ គឺ ម្ចាស់រង្វាន់។

ខ/១-ប្រសិនបើអ្នកណាមកធ្វើការបាន៨ម៉ោង/១ថ្ងៃ នឹងត្រូវទទួលបានប្រាក់រង្វាន់១០ដុល្លារ(ក្រៅពីប្រាក់ឈ្នួល)។

២-ប្រសិនបើអ្នកណាមកធ្វើការបាន៦ម៉ោង/១ថ្ងៃ នឹងត្រូវទទួលបានប្រាក់រង្វាន់០៨ដុល្លារ(ក្រៅពីប្រាក់ឈ្នួល)។

៣-ប្រសិនបើអ្នកណាមកធ្វើការបាន៤ម៉ោង/១ថ្ងៃ នឹងត្រូវទទួលបានប្រាក់រង្វាន់០៦ដុល្លារ(ក្រៅពីប្រាក់ឈ្នួល)។

នេះជាលក្ខខណ្ឌ ដែលមានកម្រិតតាមថ្នាក់ចំនួន ៣ ថ្នាក់សម្រាប់ការទទួលរង្វាន់ ដូច្នេះ បើអ្នកបានបំពេញនូវលក្ខខណ្ឌកម្រិតតាមថ្នាក់ណាមួយ អ្នកនឹងទទួលបាននូវប្រាក់រង្វាន់នេះ ផ្ទុយទៅវិញប្រសិនបើអ្នកសុំច្បាប់ឈប់សម្រាកចំនួន ១ ម៉ោង/១ថ្ងៃ ដោយមានការអនុញ្ញាតក្តី តើអ្នកបានបំពេញនូវលក្ខខណ្ឌកម្រិតថ្នាក់ណាមួយដែរ ឬទេ ? តើអ្នកអាចសុំឱ្យម្ចាស់រង្វាន់នោះ អង្គុំប្រាក់រង្វាន់សម្រាប់រូបអ្នកបានដែរ ឬទេ? មានន័យថា ការអង្គុំនោះ គឺ ១០ ចែកនឹង ៨ គុណ ៧ = ៨,៧៥ ដុល្លារ។ ចម្លើយ គឺ អ្នកមានសិទ្ធិស្នើសុំមែន ប៉ុន្តែម្ចាស់រង្វាន់ជាអ្នកសម្រេចថា ផ្តល់ជូន ឬមិនផ្តល់ជូន។

ប៉ុន្តែជាគោលការណ៍ បើអ្នកមិនបានបំពេញលក្ខខណ្ឌទេ រង្វាន់ក៏អ្នកមិនអាចទទួលបានដែរ។

## III-ការសន្និដ្ឋាន ៖

យោងតាមសេចក្តីជូនដំណឹងថ្មីលេខ ០៤១/១១ កប/សជណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ដែលបានមោឃភាពទៅលើសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ បានចែងថា *"កម្មករនិយោជិត ដែលបានមកធ្វើការទៀងទាត់តាមចំនួនថ្ងៃនៃថ្ងៃធ្វើការក្នុងខែនីមួយៗត្រូវទទួលបានប្រាក់យ៉ាងតិចចំនួន ៧ (ប្រាំពីរ) ដុល្លារអាមេរិកក្នុងមួយខែ"* ។

នេះបានបញ្ជាក់យ៉ាងច្បាស់អំពីលក្ខខណ្ឌ ដែលកម្មករនិយោជិតត្រូវបំពេញឱ្យបាន ពោលគឺត្រូវធ្វើការគ្រប់ចំនួនថ្ងៃដែលត្រូវធ្វើការក្នុងមួយខែៗនោះ ដោយត្រូវមកធ្វើការឱ្យទៀងទាត់ ទើបទទួលបានរង្វាន់ ៧ ដុល្លារអាមេរិក។

ARBITRATION COUNCIL

ក្នុងមួយខែ ប៉ុន្តែ បើកម្មករនិយោជិតមិនអាចបំពេញតាមលក្ខខណ្ឌ ហើយមានការឈប់សម្រាកដោយមិនបានមកធ្វើការនៅថ្ងៃណាមួយនោះ (មកធ្វើការងារមិនទៀងទាត់) មិនត្រូវបានទទួលប្រាក់រង្វាន់ឡើយ។ ដូច្នេះ កម្មករនិយោជិតគប្បីត្រូវតែបំពេញនូវលក្ខខណ្ឌនេះ (មកធ្វើការងារទៀងទាត់) ឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវសិន ទើបគេអាចទទួលបាននូវរង្វាន់នោះ ពីនិយោជក (ម្ចាស់រង្វាន់)។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២

ហត្ថលេខារបស់អាជ្ញាកណ្តាល

អ៊ឹង សុទ្ធី